**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៨៣
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៣

**<u>សាលដីកា</u>**
លេខ:១៩៥
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធានក្រុម
២-លោក ................ ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម
៦-លោក ................. ជាចៅក្រម
៧-លោក ................ ជាចៅក្រម
៨-លោក ................. ជាចៅក្រម
៩-លោក ................. ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា ..................

**<u>តំណាងមហាអយ្យការ</u>**

-ឯកឧត្តម .............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ៣៩ (ឃ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

ដើមចោទឈ្មោះមសរ ចុងបណ្តឹងសាទុក្ខភេទ ប្រុសអាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅ ផ្ទះលេខ១៤$E_0$ ផ្លូវលេខ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អ៊ុត ស៊ី( រ)ម្តាយឈ្មោះ អ៊ុន នោ(រ) ប្រពន្ធឈ្មោះមាស ណារី មានកូន០២នាក់ ។

និងចុងចម្លើយឈ្មោះបកសវ ដើមបណ្តឹងសាទុក្ខ ភេទប្រុសអាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ យោធា ទីលំនៅផ្ទះលេខ២៩ ភូមិព្រៃកតានួ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

ឪពុកឈ្មោះសេក ថាំង (ស) ម្តាយឈ្មោះកែវ ខឹម (ស) ប្រពន្ធឈ្មោះទឹម ស្រ៊ុន មានកូន០៦ នាក់ ។

អំពីវិវាទ ប្តឹងសុំសិទ្ធិគ្រប់គ្រងដីតាមប័ណ្ណសម្គាល់សិទ្ធិលេខ ភព០០៩៥៥ ចុះថ្ងៃទី២១-០៨-១៩៩៨ និងឱ្យឈ្មោះបកសវ រុះរើសំណង់ចេញពីដីនេះ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៨៣ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ២៥៨ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៣ របស់លោក បកសវ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៩(យ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៧-០២-២០០១ របស់លោកមសរ បានប្តឹងសុំសិទ្ធិគ្រប់គ្រងដី តាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព០០៩៥៥ ចុះថ្ងៃទី២១-០៨-៩៨ ដែលមានទីតាំងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ និងទាមទារជម្ងឺចិត្តចំនួន ៣០០០ដុល្លា ពីឈ្មោះបកសវ ដោយអាងហេតុថាដីនេះខ្លួន បានទិញពីឈ្មោះហ៊ុន ប៊ុធឿន ក្នុងឆ្នាំ១៩៩៨ ហើយបានធ្វើប័ណ្ណកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់។ប៉ុន្តែនៅក្នុងឆ្នាំ២០០០ ពេលខ្លួនធ្វើរបងព័ទ្ធដីរបស់ខ្លួនស្រាប់តែឈ្មោះបកសវ អះអាងថាខ្លួនធ្វើរបងចូលដីរបស់គាត់ទំហំ៥០ម x ៧៨ម និងបានរុះរើរបងខ្លួនចោលថែមទៀតផង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦០(ខ) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះមសរ ចុះថ្ងៃទី០៧-០២-២០០១ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ថាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព.០០៩៥៥ ចុះថ្ងៃទី២១-០៨-៩៨ របស់ឈ្មោះមសរ នាង មាស ណារី ត្រឹមត្រូវតាមច្បាប់ដែលក្នុងនោះមានដីទំនាស់ទំហំ ៥៤ម គុណ ៧៨ម ស្មើ ៤២១២ម$^2$ ផង ។

៣- ឱ្យឈ្មោះបកសវ រុះរើរោងចេញឱ្យអស់ពីដីរបស់ឈ្មោះមសរ និងឱ្យបង់សំណង ជម្ងឺចិត្តចំនួន ៣.០០០.០០០រៀល (បីលានរៀល ) ទៅឈ្មោះមសរ ចាប់ពីពេលដែលសាលក្រមនេះចូលជាស្ថាពរ ។

៤- បង្គាប់ឱ្យឈ្មោះបកសវ បង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ប្រាក់នេះបានកាត់យក ពីប្រាក់ដែលដើមចោទបានបង់រួចហើយ ពេលសាលក្រមផុតបណ្តឹងឧទ្ធរណ៍ឱ្យឈ្មោះបកសវ បង់សងវិញ។

និងបង្គាប់ឱ្យឈ្មោះបកសរ បង់ពន្ធសមាមាត្រចំនួនមួយភាគរយលើដីទំនាស់ស្មើ $\frac{៤២១២ម \times ១,៥\$}{១០០}$ = ៦៣,១៨ ដុល្លាអាមេរិក បន្ថែមទៀត ប្រាក់ពន្ធនេះត្រូវឱ្យដើមចោទបង់ទុកជាមុនផងដែរទើបបង្គាប់ ឱ្យចុងចម្លើយបង់សងវិញជាស្រេច ។

៥- សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់លោកបកសរ ប្តឹមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៦០(ខ) ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៧៨(ឈ) ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានសេចក្តីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះបកសរ ទុក ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៦០(ខ) ចុះថ្ងៃទី១៤-៦-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍១៣០០០រៀល ដែលដើមបណ្តឹងបានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងទាស់លេខ០៦ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០២ របស់លោក បកសរប្តឹងទាស់នឹងសាលដីការដ្ឋប្បវេណីលេខ១៧៨(ឈ) ចុះថ្ងៃទី១៨-១២-២០០១ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣១ (ឈ) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១១-០១-២០០២ របស់ឈ្មោះបកសរ ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីការកំបាំងមុខលេខ១៧៨ (ឈ) ចុះថ្ងៃទី១៨-១២-២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

៣- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ២៤៤ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ របស់លោកបកសរ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣១(ឈ) ចុះថ្ងៃទី០៧-០២-២០០២ របស់សាលាឧទ្ធរណ៍លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥១ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ របស់តុលាការ កំពូលដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១- ទទួលបណ្តឹងសាទុក្ខលេខ២៤៤ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ របស់លោកបកសរទុកជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៣១(ឈ)ចុះថ្ងៃទី០៧ ខែកម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៩៤ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ រប់សតុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលចុងចម្លើយបានបង់នៅតុលាការកំពូលចំនួន១៩០០០រៀល គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោងចំនួន១៥០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឱ្យដើមចោទសងប្រាក់ចំនួន១៩.០០០រៀល នេះទៅចុងចម្លើយវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៣៩(យ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលជំនុំជំរះសំណុំរឿងលេខ៣១ ចុះថ្ងៃទី០២-០៤-២០០៣ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការបស់តុលាការកំពូលលេខ៥១ ចុះថ្ងៃទី១១-០៣-២០០៣ យោងតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព នៃសាលាជំរះក្តី ។

២- ទទួលស្គាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខកព,០០៩៥៥ ចុះថ្ងៃទី២១-០៨-១៩៩៨ របស់ឈ្មោះមសរ និងនាង មាស ណារី ទុកជាត្រឹមត្រូវតាមច្បាប់ ។ ប្រគល់ដីទំនាស់ទំហំ ៥៤ម x ៧៨ម ដែលមានក្នុងប័ណ្ណខាងលើ ឱ្យទៅឈ្មោះមសរ កាន់កាប់តាមច្បាប់ ។

៣- បង្គាប់ឱ្យឈ្មោះបកសរ រុះរើរោងចេញពីដីរបស់ឈ្មោះមសរ ចាប់ពីពេលសាលដីកានេះ ចូលជាស្ថាពរ ។

៤-បង្គាប់ឱ្យឈ្មោះបកសរ បង់ពន្ធសមាមាត្រ១% លើតម្លៃដីទាស់ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី ។ បើកផ្លូវប្តឹងសាទុក្ខលើកទី២ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលើកទី២លេខ២៥៨ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់លោក បកសរ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៨(យ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើគ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការបៀបរដ្ឋប្បវេណីលេខ២៦៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១- ចាត់របៀបឱ្យធ្វើការស៊ើបសួរបន្ថែម

២-ក្នុងករណីចាំបាច់ ចាត់ចៅក្រមប្រឹក្សាតុលាការកំពូល ចុះពិនិត្យដល់ទីកន្លែងដីទំនាស់

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៩ខែធ្នូ ឆ្នាំ២០០៣ ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការបញ្ជាក់ថា:

-បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

-សំណុំរឿងនេះដែរ តុលាការកំពូល ក៏បានចាត់របៀបរួចហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោកប៊ូ ភិនសុវណ្ណ ឆ្លើយថា៖ បានជាខ្លួនប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ព្រោះសាលាឧទ្ធរណ៍កាត់ក្តីដោយអយុត្តិធម៌ ។ ដីទំនាស់នេះខ្លួនបានកាន់កាប់ និងគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយដីនេះ ក៏ជាដីរបស់ដូនតាខ្លួនយូរលង់ណាស់មកហើយ ដីនេះក៏មានអាជ្ញាធរទទួលស្គាល់ដែរ ។ លោកមសរ បានឆ្លើយបំភ្លឺនៅតុលាការថ្នាក់ក្រោមមកនោះគឺពុំត្រឹមត្រូវទេ ។ លោកមសរ និងហ៊ុន ប៊ុជឿន បានឃុបឃិតគ្នាយកឡានដឹកដីចាក់រំលោភបំពានយកដីរបស់ខ្លួន ។

សូមឱ្យតុលាការជួយរែកញែក រកយុត្តិធម៌ឱ្យខ្លួនផង

បានស្តាប់ចម្លើយរបស់លោកមសរ ឆ្លើយថា៖ បញ្ហាដីទំនាស់នេះខ្លួនបានទិញពីលោក ហ៊ុន ប៊ុនជឿន មានលិខិតស្នាមត្រឹមត្រូវ ហើយដល់ចុងឆ្នាំ៩៨ ខាងមន្ទីរសូរិយោដីក្រុងភ្នំពេញ បានចេញលិខិតលេខ០០៩៥៥ ចុះថ្ងៃទី២១-០៨-៩៨ ប្រគល់ឱ្យខ្លួនកាន់កាប់។ រយៈពេលជាង១ឆ្នាំ ក្រោយមកទើបលោក សុវណ្ណ មកសង់ខ្ទមលើដីទំនាស់នេះ ហើយខ្លួនក៏សួរគាត់ថា ហេតុអ្វីបានជាមកសង់ខ្ទមលើដីនេះ លោក សុវណ្ណឆ្លើយថា៖ មកពីលោកហ៊ុន ប៊ុនជឿន ពុំទាន់ប្រគល់លុយឱ្យគ្រប់ចំនួន ។ ហើយខ្លួនក៏បានទៅសួរលោកហ៊ុន ប៊ុនជឿន ដែល បានលក់ដីឱ្យខ្លួននេះគាត់ថាពុំបានទិញដីពីលោកបកសរទេ គឺទិញដីពីលោកទុយ សេង, លោកសោម សាមិន, លោកប៊ិន ថា លោក អ៊ុក ឡៃ ។ នៅពេលដែលខ្លួនទិញខ្លួនក៏បានដាំបង្គោលរបង និងចាក់ដី ប្រហែល៩០% ទុកតែប្រលោះខ្ទមតូចនោះទេ ដីនេះខ្លួនបានចាក់ដីជាង១ហិច

តា រួចហើយ ពេលមុនចាក់ ដីខ្លួនបានដាំត្រកួន ឈូក... ប៉ុន្តែលោកសុវណ្ណពុំដែលមកទាមទារអ្វីទេ ។ បានជាខ្លួនមិនចាក់ដីលើខ្ទមរបស់លោកសុវណ្ណនោះ ព្រោះខ្លួនយល់ថា . ប្រទេសយើងមានច្បាប់ទំលាប់ត្រឹមត្រូវ ហើយពេលខ្លួនចាក់ដីនេះលោកសុវណ្ណ ពុំបានហាមឃាត់ រឺករឿងអ្វីទេ ចំណែកដីរបស់លោកទុយ សេង ខ្លួនទិញតែ១ផ្នែកទេ ផ្នែកផ្សេងទៀត គេជាអ្នកទិញទេ ។

បានស្តាប់ចម្លើយរបស់លោកបកសវ ភ្លើយថាដីនេះ ខ្លួនបានកាន់កាប់គ្រប់គ្រងរហូតមកហើយខ្លួនក៏ពុំបានទាក់ទងអ្វីជាមួយលោកមសរដែរ ពេលចាក់ដីខ្លួនពុំបានឃាត់គាត់មែន ប៉ុន្តែខ្លួនមានឯកសារត្រឹមត្រូវ ហើយខ្លួននិយាយនេះ សុទ្ធតែពាក្យពិត ហើយក៏ពុំបានទិញឯកសារពីបុគ្គលណាទេ ។ ខ្លួនមានដីប្រវែងបណ្តោយ២៨០ម និងទទឹង១៦៣ម ហើយដៃលោកមសរ ធ្វើបេងរំលោភចូលដីខ្លួនប្រហែ៥៦x ៧៨ម ចំណែកដីដែលខ្លួនបានលក់ឱ្យលោកហ៊ុន ប៊ុនធឿន មានទំហំ៧៨ម x ២៨០ម ហើយលោកហ៊ុន ប៊ុនធឿន បានលក់ឱ្យលោកមសរ បន្តទំហំតែ៥៦មx ៧៨ម ។

បានស្តាប់លោកកែវ យ៉ា ជាមេធាវី បានឡើងសុំក្រុមប្រឹក្សាជំនុំជំរះ ដើម្បីសុំសួរសំនួរទៅលោក បកសវ ថាតើដីដែលលោកបកសវ បានលើកឡើងនេះមានទំហំប៉ុន្មាន ហើយខាងជើងមានប៉ុន្មាន ខាងត្បូងមានប៉ុន្មាន? និងតើលោកសុវណ្ណ បានដីពីណាមក បើនៅពេលលោកហ៊ុន ប៊ុនធឿន លើកផ្លូវដល់ទៅ១០ឯណោះ ?

បានស្តាប់ចម្លើយរបស់លោកបកសវ ឆ្លើយបញ្ជាក់ថា ដីដែលខ្លួនបានគ្រប់គ្រងម៉ាងអស់គឺ បណ្តោយ២៨០ម និងទទឹង១៦៣ម ។ក្នុងប្រវែង ទទឹង១៦៣ម នេះដែរគឺ បានចែកខណ្ឌជាពីរ ដែលខាងជើងមានទំហំ៧៨ម និងខាងត្បូងមានទំហំ៨៥ម ។

ចំណែកឯដីលើកផ្លូវ១០ម នោះគឺជាដីរបស់ខ្លួន ដែលធ្វើលើដីទំហំបណ្តោយ២៨០ម និង ទទឹង ១៦៣ម ហើយដីនេះជាដីបឹង ។ ដីចំនាស់មានទំហំ៧៨ម x ៥៦ម ក្នុងដីទំហំបណ្តោយ២៨០ម និងទទឹង ១៦៣ម ។ ដីសល់ពីដីទំនាស់នេះ គឺខ្លួនជាអ្នកគ្រប់គ្រងទាំងអស់ ហើយខ្លួនបានដាំឈូក ត្រកួន រហូតមក ចំណែក អាជ្ញាធរមូលដ្ឋានឃុបឃិតគ្នា រំលោភយកដីរបស់ខ្លួន ដូចនេះគេម្តេចនឹងហ៊ានឆ្លើយថា ឃើញខ្លួននៅទីនោះទៅ ។ដីដែលមានព្រំប្រទល់ខាងជើង ទល់ដីទុយ សេង និងខាងត្បូងទល់ដី សោម សាមិន គឺមិនជាន់លើដីរបស់ខ្លួនទេ ។ ខ្លួនបានលក់ដីឱ្យលោកហ៊ុន ប៊ុនធឿន មែន ប៉ុន្តែគេពុំទាន់ប្រគល់លុយឱ្យខ្លួនគ្រប់ចំនួនទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកកែវ យ៉ា ជាមេធាវីឱ្យដើមចោទ បញ្ជាក់ថា ៖

ដីរបស់កូនក្តីខ្លួនបានទិញពីលោកហ៊ុន ប៊ុនធឿន និងប្រគល់លុយឲ្យគ្រប់ចំនួនហើយក៏បានសុំសិទ្ធិកាន់កាប់រួចអស់ហើយដែរ។ ហើយមុនចុះវាស់វែងក៏បានបិទប្រកាសស្តីពីការចុះបញ្ជីកាន់កាប់ដីហើយដែរ តែគ្មានឃើញអ្នកណាមកប្តឹងឬរករឿងអ្វីឡើយ ។ លោកហ៊ុន ប៊ុនធឿន ក៏បានអះអាងដែរថា គាត់ ទិញដីពីលោកសោម សាមិន, ទុយ សេង ,ប៊ិន ថា អ៊ុក ឡៃ ទេ ពុំមែនទិញពីលោកសុវណ្ណទេ ហើយអ្នកទាំងបួនក៏

បានបញ្ជាក់ដែរថា គាត់ក៏បានកាន់កាប់រហូតមកតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ។ ហើយពួកគាត់ទាំងបួនថា ពួកគាត់ពិតជាបានលក់ដីឱ្យលោកហ៊ុន ប៊ុនធឿន ហើយគាត់បានលើកផ្លូវកាត់ចំពាក់កណ្ដាលព្រំ ហើយ គាត់ក៏ពុំបាន លើកផ្លូវលើដីរបស់លោកសុវណ្ណដែរ ។ ចំណែកលោកមសរ បានទិញដីពី លោកហ៊ុន ប៊ុន ធឿន ពិតប្រាកដមែន ដោយមានអាជ្ញាធរមូលដ្ឋានទទួលដឹងឮ និងបានបញ្ជាក់ថាលោកហ៊ុន ប៊ុនធឿ នមែន ព្រោះលោកបភសវ និងប្រពន្ធបានទទួលដី១ឡូត៍ទំហំ២៥ម×៣០ម ពីប្រធានក្រុមប្រគល់ឱ្យ លើសពីនេះ តើគាត់បានមកពីណា? សាក្សីខ្លះបញ្ជាក់ថាលោកបភសវ ពិតជាបានលក់ដីឱ្យលោក ហ៊ុន ប៊ុនធឿន មែន ហើយមិនទាន់ប្រគល់លុយឱ្យគ្រប់ចំនួននោះ ជាដីពោងពាយទេ។ មិនមែនជាដីនៅម្ដុំបឹងបាយ៉ាបទេ ។ចំណែករដ្ឋអំណាចមូលដ្ឋានបានបញ្ជាក់ថា ដីទំនាស់នេះ គឺជាដីរបស់លោកទុយ សេង អ៊ុក ឡៃ សោម សាមិន,បិន ថា មិនមែនរបស់លោកបភសវទេ ។ បើសិនជាបូកដីនេះទៅឃើញដល់ ទៅ១៧០ មជាង ហើយគាត់ថាតែ១៦៣ម ទេ ប្រវែងទទឹង ។

សូមលោក តុលាការ មេត្តាឱ្យ លោកបភសវ រុះរើផ្ទះចេញ ពីដីទំនាស់នេះ ។

សូមលោក តុលាការ មេត្តាប្រគល់ដីនេះ មកឱ្យកូនក្ដីរបស់ខ្លួន បានគ្រប់គ្រង កាន់កាប់តទៅ ។

បានស្ដាប់ចម្លើយរបស់លោកបភសវ បានឆ្លើយបន្ថែមទៀតថា ដីនេះជាដីរបស់ខ្លួនពិត ប្រាកដមែន ហើយខ្លួនក៏មានឯកសារត្រឹមត្រូវដែរ ចំណែកការលក់ដូរបស់គេនោះ គឺសុទ្ធតែមិនពិត ហើយបានឃុបឃិតគ្នារំលោភយកដីរបស់ខ្លួនទាំងអស់ ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយគូភាគី និងសេចក្ដីសន្និដ្ឋាន ការពាររបស់មេធាវីដើមចោទ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ២៥៨ ចុះថ្ងៃទី៣០-០៦-០៣ របស់ឈ្មោះប៊ូ ភិនសុវណ្ណ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកធ្វើការជំនុំជំរះរួមក្រុម បានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការរៀបចំតាំង និងសកម្មភាពរបស់សាលជំរះក្ដីនិងមាត្រា២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណី បានផងដែរ ។

- យល់ឃើញថា ដីទំនាស់ដែលមានទំហំ៥៦ម×៨៧ម ស្ថិតនៅក្នុងមូលដ្ឋានភូមិបាយ៉ាប សង្កាត់ពេញថ្មី ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញជាប្រភេទដីបឹង ដែលកាលពីមុនដីបឹងនេះត្រូវបានប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានចូលធ្វើការកាន់កាប់បង្កបង្កើនផលដំណាំឈូក ។ ការចូលកាន់កាប់នេះ ពុំមានការរារាំងពីរដ្ឋអំណាចមូលដ្ឋានឡើយ ហើយក៏ពុំមានការផ្ដល់សិទ្ធិកាន់កាប់ឱ្យប្រជាពលរដ្ឋ តាមរយៈឯកសារជាផ្លូវការ

ដែរ ។ ភាគីនីមួយៗ អាចធ្វើការអះអាងសិទ្ធិរបស់ខ្លួន ចំពោះការតតាំងនានាបានតាមរយៈការដឹងឮរបស់សាក្សី ដែលជាម្ចាស់ដីមានទី តាំងនៅជាប់ព្រំគ្នា និងការបញ្ជាក់របស់សមត្ថកិច្ចមូលដ្ឋានប៉ុណ្ណោះ ។

- យល់ឃើញថា មានភស្តុតាងបញ្ជាក់ថា ដីទំនាស់ដែលឈ្មោះប៉ូ ភិនសុវណ្ណ អះអាងថា ជាដីរបស់ខ្លួននោះ គឺជាន់ចំលើដីដែលមានម្ចាស់ដើមឈ្មោះទុយ សេង អ៊ុក ឡៃ និងបិន ថា លក់ឱ្យឈ្មោះហ៊ុន ប៊ុនធឿន ហើយឈ្មោះហ៊ុន ប៊ុនធឿន លក់បន្តឱ្យឈ្មោះមសរ នៅក្នុងកក្កដា ឆ្នាំ១៩៩៨ ដែលទំនាក់ទំនងនៃការទិញ-លក់ រវាងឈ្មោះហ៊ុន ប៊ុនធឿន និងឈ្មោះទុយ សេង, បិន ថា អ៊ុក ឡៃ ក៏ដូចជាការ ទិញ-លក់ រវាងហ៊ុន ប៊ុនធឿន និងភាគី មសរ មានកិច្ចសន្យាលាយលក្ខណ៍អក្សរ មានការបញ្ជាក់ របស់មន្ត្រីសមត្ថកិច្ចមូលដ្ឋាន នៃទីតាំងដីទំនាស់ត្រឹមត្រូវ ហើយកំពុងមានវិការៈគួរសង្ស័យថាលោកទុយ សេង បិន ថា អ៊ុក ឡៃ ពុំមែនជាម្ចាស់ដីឡើយ ដោយហេតុថា ពុកលោកគឺជាប្រជាពលរដ្ឋក្នុងមូលដ្ឋានដីទំនាស់ដែលត្រូវតែដឹងច្បាស់ពីទីតាំងដីរបស់ខ្លួន និងម្យ៉ាងទៀតមានសាក្សីដឹងឮពីសិទ្ធិភោគៈនេះ រីឯខាងលោកបភសវពុំមែនជាពលរដ្ឋក្នុងមូលដ្ឋាននេះឡើយ ហើយក៏ពុំមានឯកសារភស្តុតាងដែលបញ្ជាក់ពីសិទ្ធិភោគៈរបស់ខ្លួនលើដីទំនាស់ឡើយ ការបំភ្លឺរបស់សាក្សីចុងចម្លើយនេះ មានភាពមិនប្រាកដប្រជានិងសាក្សីខ្លួនបានឆ្លើយផ្តល់ប្រយោជន៍ឱ្យដើមចោទ ។

- យល់ឃើញថា មានសំអាងច្បាស់ថាលោក មសរ បានលទ្ធកម្មកម្មសិទ្ធិលើដីទំនាស់នេះត្រឹមត្រូវតាមច្បាប់រួចហើយ ដោយហេតុថា ក្រោយពីមានកិច្ចសន្យាទិញ លក់ ដោយមានការដឹងឮពីរដ្ឋអំណាចមូលដ្ឋានផងនោះ លោកមសរ និង លោកស្រី មាស ណារី បានចូលកាន់កាប់ដីដោយសុច្ចរិត ដោយមានធ្វើរបងចាក់ដី និងបានបង់ពន្ធដីជូនរដ្ឋ ហើយបានទទួលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព ០០៩៥៥ ចុះថ្ងៃទី២១-០៨-៩៨ របស់មន្ទីរសុរិយោដីរាជធានីភ្នំពេញ ដែលជាសមត្ថកិច្ចជំនាញ ហើយទើបតែមានការតវ៉ា ពីសំណាក់លោកបភសវ នៅដើមឆ្នាំ២០០០ ប៉ុណ្ណោះ ។

- យល់ឃើញថា លោកបភសវ បានឆ្លើយនៅក្នុងកំណត់ហេតុចុះថ្ងៃទី០៦-០១-០៤ នៅតុលាការកំពូល និងនៅពេលសវនាការនេះថា ដីរបស់លោកខាងជើងជាប់ព្រំប្រទល់នឹងលោកទុយ សេង ខាងកើតជាប់នឹងព្រំប្រទល់ លោកសោម សាមិន មិនជាន់លើដីរបស់លោកទុយ សេង និងលោក សោម សាមិនទេ។ ដូច្នេះ បញ្ជាក់ថា ការដែលលោកបភសវ បានចង្អុលបង្ហាញទំហំដី នៅក្នុងគំនូសប្លង់ ចុះថ្ងៃទី២៧-២-២០០៤ របស់ចៅក្រមតុលាការកំពូល ជាការពុំត្រឹមត្រូវទេ ពីព្រោះការចង្អុលបង្ហាញនេះ គឺហួសពីដីទុយ សេង ទៅដល់ដីអ៊ុក ឡៃ និងប៊ិន ថា ហើយខាងកើតដែលថាទល់សោម សាមិន គឺត្រូវរំលងដីអ៊ុក ឡៃ ប៊ិនថា និងទុយ សេង ។

- យល់ឃើញថា សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីឡើងវិញ តាមសាលដីការដ្ឋប្បវេណីលេខ ៣៩(យ) ចុះថ្ងៃទី១៩-០៦-០៣ នោះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលើកទី២លេខ២៥៨ ចុះថ្ងៃទី៣០-០៦-០៣ របស់ឈ្មោះបភសវ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៣៩(ឃ) ចុះថ្ងៃទី១៩-០៦-០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោកមសរ បានបង់នៅតុលាការកំពូលចំនួន១៩.០០០រៀល គឺៈ -ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យលោកបភសវ សងប្រដាក់ចំនួន១៩.០០០រៀល នេះទៅលោកមសរ វិញ ។

បង្គាប់ឱ្យលោកបភសវ បង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៤ ។